# រឿង យើងយោងបងខ្លា



# រឿង យើងយោងបងខ្លា

រឿង យើងយោងបងខ្លា

និពន្ធដោយ អ្នកស្រី ជិន យ៉ាហាន

គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្មគ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០១១



នៅចន្លោះភ្នំធំពីរនោះ មានជ្រលងតូចមួយ តែជ្រៅស្រទប់ ។





កូនខ្លានៅមាត់ជ្រលងម្ខាង កំពុងអើតមើលកូនខ្លាឃ្មុំ កូនក្ដាន់ កូនដំរី កូនជ្រូកព្រៃ កូនចចក កូនទន្សាយ និងកូនចាបដែលកំពុងប្រឡែងលេងជាមួយគ្នា ។







ពេលនោះ កូនខ្លាស្រែកពីមាត់ជ្រលងម្ខាងថា៖

- សួស្តីប្អូនៗ ឱ្យបងសុំលេងជាមួយផង បងនៅឯនេះតែម្នាក់ឯង គ្មានមិត្តភក្តិលេងជាមួយទេ ។
- បាទ! សួស្តីបងខ្លា សូមបងមកលេងជាមួយពួកខ្ញុំមក(កូនខ្លាឃ្មុំឆ្លើយ) ។



កូនខ្លាឮហើយ ក៏ស្រែកសួរថា៖

- អរគុណហើយប្អូនខ្លាឃ្មុំ តើធ្វើយ៉ាងណា ទើបបងអាចទៅដល់កន្លែងប្អូនបាន?

- សូមបងខ្លាហក់មក ពួកយើងចាំទទួលបង(កូនជ្រូកព្រៃឆ្លើយ) ។

- មិនបានទេ បងខ្លាហក់មិនដល់ទេ! ជ្រលងភ្នំនេះធំបន្តិចហើយសម្រាប់បងខ្លា (កូនទន្សាយឃាត់) ។





កូនខ្លាដើររេរាៗ មិនហ៊ានហក់ឆ្លងទេ ។
- បងខ្លា! បងនៅចាំបន្តិចសិន ខ្ញុំរកមធ្យោបាយឃើញហើយ
( កូនដំរីស្រែកឡើង )។





កូនដំរីដើរចូលទៅក្នុងព្រៃមួយសន្ទុះ   ហើយពេលចេញមកវិញ  ក៏មាន ដើមឫស្សី  កំណាត់ឈើតូចធំ  ខ្លីវែង ព្រមទាំងវល្លិយកមកជាមួយផង ដើម្បី ធ្វើប្រដាប់ទាញកូនខ្លា ។





លុះធ្វើជងដោយបានរួចហើយ កូនដំរីស្រែកប្រាប់កូនខ្លាថា៖

- សូមបងខ្លាឡើងអង្គុយលើសង្រែកនេះទៅ ហើយនៅឱ្យស្ងៀម ពួកយើងនឹងទាញបង យកមកលេងជាមួយពួកយើង ។





បន្ទាប់មក កូនដំរីក៏ងាកមកស្រែកសួរមិត្តទាំងអស់គ្នាថា៖

- អ្នកទាំងអស់គ្នា! ចូរឡើងមកអង្គុយលើគល់ដងដោយនេះមក ខ្ញុំន្ទាលនឹងទាញបង្វែរដងដោយនេះ នាំបងខ្លាបានមកលេង ជាមួយពួកយើង ។





កូនជ្រូកព្រៃឡើងអង្គុយមុនគេ  បន្ទាប់មកកូនចចក រួចហើយកូនខ្លាឃ្មុំ កូនក្តាន់ និងទន្សាយ ។ ប៉ុន្តែទម្ងន់អ្នកទាំងប្រាំ នៅស្មើរមិនអាចធ្វើឱ្យចុងដងដោយបះឡើងបានឡើយ ។ កូនដំរីក៏ស្រែកប្រាប់កូនចាបឱ្យទៅទំបន្ថែមទៀត ។ ពេលនោះ ចុងដងដោយខាងកូនខ្លា ហើបឡើងបន្តិចផុតពីដី ។





- ជយោ! បងខ្លាហើបហើយ ( ទាំងអស់គ្នាស្រែកឡើង ) ។
បន្ទាប់មក  កូនដំរីក៏ចាប់ទាញខ្សែធ្វើឱ្យជងដោយងាកបន្តិចម្តងៗ យោងកូនខ្លាឆ្លងជ្រលងភ្នំ  រហូតបានមកជួបជុំគ្នា ។





- បងខ្លាមកដល់ហើយ  សួស្តីបងខ្លា! (កូនទន្សាយនិយាយ) ។
- សួស្តីអ្នកទាំងអស់គ្នា  ខ្ញុំសូមអរគុណច្រើន  មក៍! យើងលេងជាមួយគ្នា (កូនខ្លាឆ្លើយ) ។





លុះដល់ពេលល្ងាច មិត្តទាំងអស់ក៏បង្វែរដងដោយនាំបងខ្លាវិលត្រឡប់ទៅមាត់ជ្រលងម្ខាងវិញ ។ មេខ្លាមកពីរកចំណី ឈររង់ចាំទទួលកូនត្រឡប់មកវិញដោយទឹកមុខញញឹម ហើយនិយាយថា "អរគុណហើយក្មួយៗ ដែលបានរាប់អាន និងលេងជាមួយកូនខ្ញុំ" ៕

ចប់







អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association
*Move forward, hand in hand.*